ព្រះតេជព្រះគុណបណ្ឌិត
ម្យុក សាវណ្ណ

ប្រវត្តិរូបសង្ខេប
របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ
ព្រះចៅអធិការវត្តខ្មែរកោណាដា

ប្រសូត្រនៅថ្ងៃ១០មីនាឆ្នាំ១៩៤០ នៅឃុំព្រៃកប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា, ព្រះតេជព្រះគុណបណ្ឌិត ម្យុក សាវណ្ណ ជាបុត្រទីបីក្នុងបណ្តាបុត្រ៩នាក់ បិតានាម ហុក ហៃ មាតានាម សុខ យឹម។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរ លុះព្រះជន្ម២១ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ។បន្ទាប់ពីព្រឹត្តិការណ៍ឆ្នាំ១៩៧៥ ព្រះតេជព្រះគុណបណ្ឌិត ម្យុក សាវណ្ណ បាននិមន្តភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបាននិមន្តទៅរស់នៅទីក្រុងម៉ុងរេអាលប្រទេសកាណាដានៅថ្ងៃ២៣មេសាឆ្នាំ១៩៨១ រហូតដល់ឆ្នាំ២០០៤នេះ ។

កម្រឹតវិជ្ជា

ព្រះតេជព្រះគុណបន្ឌិត ម្យុក សាវណ្ណ កាលពីកុមារភាព បានសិក្សាអក្សរសាស្រ្តជាតិចប់បឋមសិក្សា។បន្ទាប់ពីបានបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសាលាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក ។ បានសិក្សាចប់ពុទ្ធិកបឋមសិក្សា ដែលពីដើមហៅថា សាលាបាលីរង ចប់ពុទ្ធិកមធ្យមសិក្សាគឺឌីប្លូមនិងបាក់ឌុប, ចប់ពុទ្ធិកឧត្តមសិក្សាគឺបរិញ្ញាបត្រ ដែលភាសាអង់គ្លេសហៅថា (Bachelor degree) នៅពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជភ្នំពេញផ្នែកទស្សនវិជ្ជានិងបុរាណភាសាបាលីសំស្រ្កឹត, បានសិក្សាអក្សរសាស្រ្តនិងមនុស្សសាស្រ្តនៅមហាវិទ្យាល័យអក្សរសាស្រ្តនៃសាកលវិទ្យាល័យភ្នំពេញជាមួយនិស្សិតជាគ្រហស្ថ តែពុំបានចប់ដោយព្រឹត្តិការណ៍ឆ្នាំ១៩៧៥ ។ ក្រៅពីសិក្សាផ្នែកគន្ថធុរៈ,ព្រះតេជព្រះគុណ ម្យុក សា វណ្ណ បានអប់រំចិត្តផ្នែកវិបស្សនាធុរៈអស់កាលជាច្រើនឆ្នាំ។ កាលនៅកំពុងសិក្សាបានបោះឆ្នោតជាប់ធ្វើជាប្រធានសមាគមសមណនិស្សិតខ្មែរនៅភ្នំពេញ។ បានធ្វើជាសាស្រ្តាចារ្យបង្រៀនខាងអក្សរសាស្រ្តជាតិនៅពុទ្ធិកវិទ្យាល័យធម្មទូត ដែលវិទ្យាល័យនេះបង្កើតឡើងដោយព្រះតេជព្រះគុណ តោ អាន។នៅបរទេស ព្រះតេជព្រះគុណ ម្យុក សាវណ្ណ បន្តការសិក្សារហូតជាប់ថ្នាក់បណ្ឌិតទស្សនវិជ្ជាផ្នែកព្រះពុទ្ធសាសនា(Doctor of Philosophy in Buddhism) នៅសាកលវិទ្យាល័យ ញូដែល្លី ប្រទេសឥណ្ឌា កាលពីថ្ងៃទី២៨កុម្ភៈ ឆ្នាំ២០០៤ ៕

ក្រុងម៉ុងរេអាល,ថ្ងៃទី២៥មេសា ឆ្នាំ២០០៤

សកម្មភាពសម្រាប់សង្គមខ្មែររបស់ព្រះបណ្ឌិត ហុក សាវណ្ណ

កាលពីឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៨១នៅជំរុំនានានៃប្រទេសថៃ ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ បានទេសនាណែនាំជនជាតិខ្មែរដែលភៀសខ្លួននៅទីនោះ តាមវិធីពុទ្ធសាសនាឱ្យមានកម្លាំងផ្លូវចិត្តឡើងវិញ បន្ទាប់ពីបានទទួលរងគ្រោះក្នុងសម័យខ្មែរក្រហមឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

-បានកសាងវត្តមួយនៅទីក្រុងម៉ុងរេអាលប្រទេសកាណាដា ដើម្បីរក្សាប្រពៃណីទំនៀមទម្លាប់ព្រះពុទ្ធសាសនានៅទីនោះឱ្យបានគង់វង្ស ។

-បានផ្តួចផ្តើមគំនិតបបួលព្រះសង្ឃខ្មែរឱ្យកសាងពុទ្ធមណ្ឌលមួយនៅព្រះរាជាណាចក្រកម្ពុជា មាតុភូមិ តាំងពីឆ្នាំ១៩៩៦។ ឥឡូវនេះ ពុទ្ធមណ្ឌលនោះ បានកើតជារូបរាងហើយ នៅឃុំ ជីអិដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលមានទំហំដី១០០ហិកតា ដោយសហការគ្នា កសាងរវាងព្រះសង្ឃនិងពុទ្ធបរិស័ទខ្មែរទាំងក្នុងប្រទេសនិងក្រៅប្រទេស ។

-បានធ្វើជាអគ្គលេខាធិការនៃមហាសន្និបាតព្រះសង្ឃ នៅក្រៅប្រទេសអស់កាលជាច្រើនឆ្នាំ រហូតដល់ឆ្នាំ១៩៩៥ ។

-បានធ្វើជាប្រធានគណៈកម្មាធិការស្វែងរកយុត្តិធម៌ និងប្រជាធិបតេយ្យ ជូនប្រជាពលរដ្ឋខ្មែរ នៅព្រះរាជាណាចក្រកម្ពុជា។

-បានធ្វើធម្មសាកច្ឆាតាមវិទ្យុសម្លេងសហរដ្ឋអាមេរិកសំរាប់អ្នកស្តាប់នៅប្រទេសកម្ពុជាជារៀងរាល់សប្តាហ៍ ដើម្បីរំលឹកបំភ្លឺស្មារតីប្រជាពលរដ្ឋនិងអ្នកដឹកនាំខ្មែរក្នុងការរក្សាការពារកម្ពុជា មាតុភូមិ ឱ្យបានគង់វង្សនិងសុខសន្តិភាពល្អូតលាស់ចំរើន តាំងតែពីឆ្នាំ១៩៨៥ដល់ឆ្នាំ១៩៩៥ ។តមកទៀត,បានធ្វើធម្មសាកច្ឆាតាមវិទ្យុអាស៊ីសេរីជាច្រើនឆ្នាំទៀត។

-ព្រះអង្គបានក្រៅពីនេះ,ត្រូវសមាគមនានានៅសហរដ្ឋអាមេរិកនិមន្តឱ្យធ្វើបាឋកថាស្តីអំពីផ្លូវពុទ្ធចក្រសំរាប់ជួយសង្គមខ្មែរ។មិនតែប៉ុណ្ណោះ ព្រះអង្គបានទទួល និមន្តទៅទេសនាក្នុងពិធីបុណ្យធំៗរបស់ខ្មែរនៅសហរដ្ឋអាមេរិក ប្រទេសបារាំង ប្រទេសអូស្រ្តាលី ជាដើម ។

-ព្រះអង្គបាននិមន្តទៅធ្វើទស្សនកិច្ចនៅប្រទេស កាន់ព្រះពុទ្ធសាសនាជាច្រើនដូចជាប្រទេសឥណ្ឌា ថៃ, សេរីលង្កា, ភូមា, នេប៉ាល ដើម្បី ពិនិត្យមើលការប្រតិបត្តិ ព្រះពុទ្ធសាសនានៃប្រទេសទាំងនោះ កន្លែងណាល្អ យកមកឆ្នៃរៀប ចំព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាឱ្យបានល្អូតលាស់ចំរើនឡើងថែមទៀត ។

-តាំងពីបានកសាងវត្តខ្មែរកាណាដានៅក្រុងម៉ុងរេអាល ព្រះបណ្ឌិតហុក សាវណ្ណ បានបើកសាលាបង្រៀនអក្សរសាស្រ្តជាតិ សិល្បៈខ្មែរ ដល់កុមារា_កុមារី យ៉ាងច្រើនឆ្នាំ ក្នុងគោលដៅបណ្តុះបណ្តាល " ទំពាំងស្នងឫស្សី " ឱ្យមានឧត្តមគតិរក្សាតម្លៃជាតិមាតុភូមិ ហាក់ដូចព្រះអង្គមិនចេះហត់នឿយទាល់តែសោះ ។

-ព្រះអង្គតែងសំដែងព្រះហឫទ័យគាំទ្រការតស៊ូតាមសន្តិវិធី អហិង្សានិងតាមច្បាប់អន្តរជាតិរបស់ជនរួមឈាមខ្មែរកម្ពុជាក្រោមក្នុងបំណងរកសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង។មេសា០៤_៩៦ ។

Heureuses salutations de tous les fidèles adressées au Vénérable Docteur Hok Savann

Au nom du Commité des Sages de la Fédération Mondiale du Khmer Kampuchea-Krom et en mon nom personnel, je salue très respectueusement le Vénérable Docteur Hok Savann, Supérieur de la Pagode Khmère du Canada à Montréal, Québec, et lui exprime toutes mes respectueuses et sincères félicitations accompagnées de joie profonde pour son obtention du diplôme de Doctorat en Philosophie bouddhique à l'Université de New Delhi, en Inde,le 28 Février 2004 .

Je lui adresse également nos voeux de progrès dans tous les domaines, de bonne santé en tout temps, de vitalité, de longivité centenaire pour répandre davantage le bouddhisme dont l'enseignement directeur prône la non violence et la paix spirituelle à toute l'humanité et particulièrement aux Khmers à travers le monde. La remise de ce doctorat par l'Université de New Delhi constitue un témoignage vivant des efforts inlassables et déterminés de la part du Vénérable Docteur Hok Savann dans ses études , malgré l'entre-deux âges et malgré un emploi du temps surchargé dûs à ses devoirs sacerdotaux auprès de ses innombrables fidèles. Ce vénérable s'est montré

exceptionnellement exemplaire à ses fidèles qui sont aux études , qu'ils soient laïques ou religieux. En Inde, patrie du Bouddha,le vénérable Hok Savann a fait l'honneur de tout le clergé khmer car pour la première fois dans l'histoire de ce pays, un bonze cambodgien reçoit un doctorat en philosophie bouddhique .

Le vénérable Docteur Hok Savann est connu internationalement, particulièrement en Amérique du Nord, par son oeuvre de prédication visant à marquer à tous ses fidèles les lois tracées par l'Enseignement du du Bouddha ainsi que le sens civique et également pour réalisation en cours du Centre Bouddhique au Royaume du Cambodge, une oeuvre illustre pour pérenniser le Bouddhisme qui constitue une force psychologique et morale primordiale pour la sauvegarde de l'intégrité territoriale, de l'indépendance du Cambodge aux voeux du peuple khmer et conforme à la justice de l'humanité. Il est à remarquer que depuis la construction des Ruines d'Ankor au 12è siècle, la Nation Khmère n'a bâti jusqu'à date, aucune oeuvre digne du patrimoine. Ainsi, le Centre Bouddhique en cours de construction au Royaume du Cambodge fera partie intégrale de notre patrimoine. Ceci grâce aux grandes idées, à un haut degré d'instruction et aux sacrifices .

Au nom du Commité des Sages de la Fédération Mondiale du Kampuchea-Krom et en mon nom personnel, je prie respectueusement le vénérable docteur Hok Savann de bien vouloir agréer l'expression de notre profond respect et accepter nos voeux de réussites en tout temps et ainsi que les supports de tous les fidèles. Tous nos meilleurs souhaits pour la Nouvelle Année Khmère de l'ère bouddhique 2548 .

Fait à Montréal, le ler Avril 2004
Pour C.S.F.M.K.K. : Thach Chanh